ការប្តេជ្ញាចិត្តមកលើសុវត្ថិភាពនៃសិស្ស

ជម្រាបជូនសហគមន៍ LBUSD,

នៅពេលសាលារៀនបានបើកឡើងវិញក្នុងឆ្នាំសិក្សានេះ បន្ទាប់ពីអស់រយៈពេលមួយឆ្នាំកន្លះផុតទៅ ដែលសិស្ស LBUSD ភាគច្រើនបានចំណាយរៀននៅតាមផ្ទះ គឺលទ្ធផលបាននាំមកជាកម្រិតខ្ពស់ច្រើន លាយជាមួយកម្រិតទាបជាទីបំផុតខ្លះៗទៀត ។ អ្វីមួយក្នុងចំណោមកម្រិតទាបជាទីបំផុត គឺបានកើតឡើងពីថ្ងៃរសៀលម្សិលមិញ នៅពេលភ្នាក់ងារប៉ូលីស LBUSD ម្នាក់បានរាលកៃកាំភ្លើង ក្នុងពេលគាត់កំពុងបំបែកការជម្លោះមួយជាប់នៅជ្រុងផ្លូវ Spring Street និង Palo Verde Avenue ។ ហេតុការណ៍នេះមានភាពប៉ះទង្គិចយ៉ាងខ្លាំងមកកាន់សហគមន៍សាលារៀនរបស់យើង ហើយយើងកំពុងធ្វើការនឹកគិតគូររួមគ្នាទៅកាន់អ្នករងគ្រោះ ។

នៅក្នុង LBUSD គឺយើងយកចិត្តទុកដាក់យ៉ាងជិតដល់មកលើសុខភាព និង សុវត្ថិភាពនៃបុគ្គលិក និង សិស្សរបស់យើង ។ ទោះបីម្នាក់ៗមានមុខងារជាអ្វីក៏ដោយ ក៏បុគ្គលិករបស់យើងយល់ដឹងថា សុវត្ថិភាពនៃសិស្ស និង បុគ្គលិក គឺជាគ្រឹះនៃកិច្ចការរៀងរាល់ថ្ងៃរបស់យើង ។ ហេតុការណ៍ពីម្សិលមិញប្រហែលជាធ្វើឱ្យលោកអ្នកមួយចំនួនមានការសង្ស័យមកលើសុវត្ថិភាពនៃសិស្សរបស់លោកអ្នក ។ យើងនៅតែបន្តការប្រឹងប្រែងបំពេញកិច្ចការ ដើម្បីបញ្ជាក់ថា លោកអ្នកនឹងគ្មានសំនួរអ្វីមកកាន់ការប្តេជ្ញាចិត្តរបស់យើងនោះទេ ។ ចំពោះសិស្សទាំងឡាយណា ដែលបានទទួលការប៉ះទង្គិចដោយហេតុការណ៍នេះ គឺយើងស្នើសុំឱ្យពួកគេស្វែងរកជំនួយអប់រំពីអ្នកផ្តល់ឱវាទនៅតាមសាលារៀនរបស់ពួកគេ ។

ភ្នាក់ងារប៉ូលីសសាលារៀនរបស់យើងត្រូវបានជួលមកធ្វើការសម្រាប់ការពារផ្នែកសន្តិសុខនៃបុគ្គលិក និង សិស្សរបស់យើងនៅក្នុង និង ជុំវិញបរិវេណនៃសាលារៀន ។ ពួកគេបានទទួលការហ្វឹកហាត់យ៉ាងច្បាស់លាស់ និង ទទួលមុខងារខុសត្រូវស្របខ្នាតគំរូអាជីព ។ ខ្នាតគំរូទាំងអស់នោះនឹងលើកយកមកប្រើ ដើម្បីធ្វើការថ្លឹងថ្លែងមើលអំពីហេតុការណ៍បានកើតឡើងពីម្សិលមិញ ។

ដូចជាលោកអ្នកភាគច្រើននោះដែរ គឺខ្ញុំមានទុក្ខព្រួយនៅថ្ងៃនេះ ។ និងដោយសារទុក្ខព្រួយរបស់ខ្ញុំ គឺខ្ញុំនឹងបង្ហាញការគាំទ្រយ៉ាងមាំមួនជាបន្តទៅកាន់ក្រុមគ្រួសារ ឡុងប៊ីច របស់យើង ដើម្បីបំពេញកិច្ចការរៀងរាល់ថ្ងៃជួយសិស្សរបស់យើងទាំងអស់សម្រាប់ឱ្យពួកគេមានភាពកក់ក្តៅក្នុងការទទួលសុវត្ថិភាព ទទួលការមើលឃើញ ទទួលការយកចិត្តទុកដាក់ស្តាប់ និង ទទួលជំនួយនៅតាមសាលារៀនរបស់ពួកគេ និងនៅក្នុងសហគមន៍របស់យើង ។

ដោយសេចក្តីគោរព,

Jill Baker
អគ្គនាយកសាលារៀន